**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខៈ ៥០២ កបទ.សអ.បល

ថ្ងៃអង្គារ ១០រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង

គណៈកម្មការរៀបចំការប្រឡងជ្រើសរើសមន្ត្រីក្របខណ្ឌថ្មីឆ្នាំ២០១៩ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមជូនដំណឹងដល់បេក្ខជន-បេក្ខនារី ដូចមានរាយនាមក្នុងបញ្ជីឈ្មោះបិទផ្សាយឲ្យបានជ្រាបថា ការប្រឡង**វិញ្ញាសាសរសេរ**នឹងប្រព្រឹត្តទៅរយៈពេល០៤ម៉ោង នៅថ្ងៃសៅរ៍ ៦កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (ច្រកទ្វារខាងត្បូង) ដូចខាងក្រោមៈ

ក. បេក្ខជន/នារី ប្រឡង**ភាសាអង់គ្លេស** ចូលតាមច្រកទ្វារ **"ក"**

ខ. បេក្ខជន/នារី ប្រឡង**ភាសាផ្សេងៗ** ចូលតាមច្រកទ្វារ **"ខ"**

គ. បេក្ខជន/នារី ប្រឡងជំនាញ**ហិរញ្ញវត្ថុ គណនេយ្យ និងព័ត៌មានវិទ្យា** ចូលតាមច្រកទ្វារ **"គ"**

បញ្ជាក់ ៖

- បេក្ខជន/នារី ត្រូវមកដល់មណ្ឌលប្រឡងនៅម៉ោង ៦:៣០ នាទីព្រឹក ជាកំហិត
- បេក្ខជន/នារី ត្រូវបង្ហាញសលាកប័ត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន សំបុត្របញ្ជាក់កំណើត ឆាយ៉ា មុនពេលចូលបន្ទប់ប្រឡង
- ទូរស័ព្ទ នាឡិកាអេឡិចត្រូនិក ឯកសារ និងសំភារៈផ្សេងៗ ខុសពីការផ្តល់ជូនដោយគណៈកម្មការរៀបចំការប្រឡងមិនត្រូវបានអនុញ្ញាតឲ្យយកចូលក្នុងមណ្ឌលប្រឡងឡើយ
- ព័ត៌មានផ្សេងៗអាចទាក់ទងនាយកដ្ឋានបុគ្គលិករៀងរាល់ម៉ោងធ្វើការ។

**ជ.ប្រធានគណៈកម្មការរៀបចំការប្រឡង**
**អនុប្រធាន**

**អ៊ុច បូររិទ្ធ**

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh